ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៥១៣.០២១.២៧៥ ធ.ជ.ណ

*ថ្ងៃ អង្គារ ៩កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២១*

# សេចក្ដីជូនដំណឹង
## ស្ដីពី ការលើកទឹកចិត្តឱ្យប្រើប្រាស់សេវាអេឡិចត្រូនិក

ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលកំពុងរាតត្បាតយ៉ាងធ្ងន់ធ្ងរនៅក្នុងសហគមន៍ ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តវិធានការការពារហានិភ័យដែលអាចកើតឡើងជាយថាហេតុដោយសារការប្រើប្រាស់ក្រដាសប្រាក់ តាមរយៈការសម្លាប់មេរោគនៅលើក្រដាសប្រាក់រៀលដែលចូលមកធនាគារជាតិនៃកម្ពុជា ហើយបញ្ចេញក្រដាសប្រាក់ដែលសម្លាប់មេរោគរួចទៅក្នុងទីផ្សារវិញ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏សូមបន្តលើកទឹកចិត្តក្នុងការកាត់បន្ថយការប្រើប្រាស់ក្រដាសប្រាក់ ក៏ដូចជាការប្រើប្រាស់/ចេញផ្សាយមូលប្បទានប័ត្រ សម្រាប់ធ្វើការផាត់ទាត់និងទូទាត់នានា ហើយជំនួសវិញដោយការប្រើប្រាស់ការទូទាត់អេឡិចត្រូនិកតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ការប្រើប្រាស់សេវាទូទាត់អេឡិចត្រូនិក ដូចជាសេវាធនាគារតាមកម្មវិធីទូរស័ព្ទចល័ត ក៏ដូចជាកម្មវិធីបាគងដែលជាប្រព័ន្ធទូទាត់បែបទំនើបថ្មីមួយ នឹងផ្ដល់សុវត្ថិភាពខ្ពស់ ភាពងាយស្រួល ឆាប់រហ័ស និងចំណាយតិចផងដែរ។

ធនាគារជាតិនៃកម្ពុជាសង្ឃឹមថា សាធារណជនទាំងអស់នឹងចូលរួមសហការកាត់បន្ថយហានិភ័យទាំងអស់គ្នា ជាពិសេសតាមរយៈការប្រើប្រាស់មធ្យោបាយទូទាត់អេឡិចត្រូនិកទំនើបៗនិងសម្បូរបែប ដែលមាននាពេលបច្ចុប្បន្ន និងសូមអនុវត្តនូវវិធានការ ៣ ការពារ ៣ កុំ និងការណែនាំនានារបស់ក្រសួងសុខាភិបាលឱ្យបានខ្ជាប់ខ្ជួន។

**សូមទំនាក់ទំនង៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh